# សេចក្តីប្រកាសទទួលពាក្យស្នើសុំ៖
# «មូលនិធិដំឡើងស្នាដៃថ្មី ឆ្នាំ២០២៤ »
## ស្នាដៃសិល្បទស្សនីយភាព ក្រោមមូលបទ «សិល្បៈនិងសង្គម»

សិល្បៈខ្មែរអមតៈ

**ព័ត៌មានសំខាន់ៗ**

| | |
|---|---|
| **ឱកាស** | មូលនិធិ **«មូលនិធិដំឡើងស្នាដៃថ្មី ឆ្នាំ២០២៤»** |
| **បង្កើតឡើងដើម្បី** | គាំទ្រដល់សិល្បករជាឯកត្តជនឬសិល្បករជាក្រុម ក្នុងទម្រង់សិល្បទស្សនីយភាព ក្រោមមូលបទ «សិល្បៈនិងសង្គម» |
| **ចំនួនដែលត្រូវជ្រើសរើស** | ៤ កន្លែង |
| **គម្រោង & រយៈពេល** | គម្រោងត្រូវតែកើតឡើងនៅចន្លោះពី ខែកក្កដា ដល់ ខែធ្នូ ឆ្នាំ ២០២៤ |
| **កាលបរិច្ឆេទសំខាន់ៗ** | **ដំណាក់កាលទី ១ ៖** ថ្ងៃទី ២១ ខែឧសភា ឆ្នាំ ២០២៤ - ការបើកប្រកាសទទួលពាក្យស្នើសុំមូលនិធិដំឡើងស្នាដៃថ្មី<br>**ដំណាក់កាលទី ២ ៖** ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០២៤ - ការបិទទទួលពាក្យ<br>**ដំណាក់កាលទី ៣ ៖** ថ្ងៃទី ៩ ខែកក្កដា ឆ្នាំ ២០២៤ - ការប្រកាសអ្នកទទួលបានមូលនិធិ |
| **ចំនួនថវិកា** | ៦.០០០ ដុល្លារអាមេរិក |

**មូលនិធិ «ដំឡើងស្នាដៃថ្មី»**

សិល្បៈខ្មែរអមតៈមានសេចក្តីរីករាយនឹងប្រកាសបើកមូលនិធិ **«ដំឡើងស្នាដៃថ្មី ឆ្នាំ២០២៤»** ក្រោមមូលបទ "សិល្បៈនិងសង្គម" ដើម្បីផ្តល់ឱកាសដល់សិល្បករជាឯកត្តជន ឬសិល្បករជាក្រុម ក្នុងការបង្កើតស្នាដៃសិល្បទស្សនីយភាពថ្មី ។ មូលនិធិនឹងត្រូវបានប្រគល់ជូនបេក្ខជនចំនួន ៤ នាក់/ក្រុម ដើម្បីយកទៅប្រើប្រាស់ក្នុងការអនុវត្តគម្រោង **នៅចន្លោះពី ខែកក្កដា ដល់ពាក់កណ្តាល ខែធ្នូ ឆ្នាំ២០២៤** ។

**១. វត្ថុបំណងរបស់មូលនិធិ**

មូលនិធិ **«ដំឡើងស្នាដៃថ្មី»** បង្កើតឡើងក្នុងវត្ថុបំណងដូចខាងក្រោម៖

- លើកទឹកចិត្តសិល្បករឱ្យបង្កើតភាពច្នៃប្រតិដ្ឋកាន់តែច្រើន តាមរយៈការបង្កើតស្នាដៃថ្មី ឬ ការអភិវឌ្ឍស្នាដៃថ្មីដែលមានស្រាប់ ។
- ជួយបង្កើតជាវេទិកាមួយសម្រាប់សិល្បករធ្វើការចែករំលែក និងឆ្លុះបញ្ចាំងអំពីសង្គមកម្ពុជានាពេលបច្ចុប្បន្ន តាមរយៈស្នាដៃច្នៃប្រតិដ្ឋរបស់ខ្លួន ។
- ចូលរួមអភិវឌ្ឍជំនាញវិជ្ជាជីវៈរបស់សិល្បករ ។

**២. អត្ថប្រយោជន៍**

សិល្បករ នឹងទទួលបានទឹកប្រាក់រហូតដល់ ៦.០០០ ដុល្លារអាមេរិក សម្រាប់យកទៅចំណាយលើ៖

- ទឹកប្រាក់ចំនួន **៤.០០០ ដុល្លារអាមេរិក** សម្រាប់ចំណាយលើដំណើរការនៃការដំឡើងស្នាដៃថ្មី
- ទឹកប្រាក់ចំនួន **១.០០០ ដុល្លារអាមេរិក** សម្រាប់ចំណាយលើអ្នកប្រឹក្សាយោបល់ផ្នែកសិល្បៈ
- ទឹកប្រាក់ចំនួន **១.០០០ ដុល្លារអាមេរិក** សម្រាប់ចំណាយលើការបង្ហាញឬសម្តែងស្នាដៃនៅពេលបញ្ចប់ (កុងត្រាដាច់ដោយឡែក)

**៣. សិល្បករគោលដៅសម្រាប់ផ្តល់មូលនិធិ**

- សិល្បករវ័យក្មេង ឬ ជាសិល្បករមានពិសោធន៍ច្រើនគួរសម ហើយមានការតាំងចិត្តខ្ពស់ចំពោះអាជីពរបស់ខ្លួន
- សិល្បករដែលធ្វើការក្នុងផ្នែកសិល្បទស្សនីយភាព (មានដូចជា ល្ខោន របាំ តន្ត្រី) ឬជាសិល្បករដែលធ្វើការលើពហុទម្រង់តែត្រូវតែយកទម្រង់សិល្បទស្សនីយភាពជាគោល (ដូចជា៖ ល្ខោននិងសិល្បៈបង្គុំ, តន្ត្រីនិងគំនូរ, របាំនិងកុន ។ល។)

- សិល្បករឯកត្តបុគ្គល ឬ ជាក្រុមសិល្បករ ឬ ជាសិល្បៈសហគមន៍ (ចំពោះក្រុមសិល្បករឬសិល្បៈសហគមន៍ សូមដាក់ឈ្មោះតែអ្នកតំណាងក្រុមបានហើយនៅក្នុងពាក្យស្នើសុំ)

**៤. លក្ខខណ្ឌជ្រើសរើស**

ដើម្បីអាចដាក់ពាក្យស្នើសុំមូលនិធិដំឡើងស្នាដៃថ្មីបាន បេជនក្ខជនត្រូវតែមានលក្ខណៈគ្រប់គ្រាន់ទៅតាមលក្ខខណ្ឌដូចខាងក្រោម៖

- ស្នាដៃដែលគ្រោងបង្កើតថ្មី ឬក៏ជាស្នាដៃបង្កើតថ្មីដែលមានស្រាប់ តែត្រូវការការអភិវឌ្ឍបន្ថែម ។រីឯស្នាដៃដែលមានស្រាប់ ហើយពុំមានគម្រោងយកមកអភិវឌ្ឍបន្ថែមនោះទេ ស្នាដៃនោះពុំមានសិទ្ធិស្នើសុំមូលនិធិបានឡើយ ។
- បេក្ខជន អាចដាក់ពាក្យស្នើសុំជាលក្ខណៈបុគ្គល ឬ ជាក្រុម តែក្រុមនោះមិនត្រូវមានសមាជិកលើសពី ៨ នាក់ឡើយ ។
- ស្នាដៃដែលមានរយៈពេលសម្តែងចន្លោះ ៣០ នាទី ទៅ ៤៥ នាទី ។
- ពាក្យស្នើសុំ អាចសរសេរជាភាសាខ្មែរក៏បាន ឬ ភាសាអង់គ្លេសក៏បាន ឬ ថតចម្លើយជាវីដេអូក៏បាន ឬ ជាសំឡេងក៏បាន ហើយអាចសរសេរដៃក៏បានឬដោយកុំព្យូទ័រក៏បាន ។ ប្រសិនបើបេក្ខជនមានការលំបាកក្នុងការបំពេញពាក្យស្នើសុំ សូមអញ្ជើញទាក់ទងមកលេខ **០១០ ៤៨៣ ៩៤៧/០៧៧ ៧៩៣ ៥៣៧** ។
- ចូរបញ្ជូន ពាក្យស្នើសុំ តាមរយៈអ៊ីម៉ែល **samath@cambodianlivingarts.org** ឬអាចយកពាក្យស្នើសុំទៅដាក់ផ្ទាល់នៅការិយាល័យអង្គការសិល្បៈខ្មែរអមតៈក៏បាន (អាសយដ្ឋានការិយាល័យអង្គការសិល្បៈខ្មែរអមតៈ ៖ **ផ្ទះលេខ១៣E ផ្លូវលេខ៨៣០ សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន ភ្នំពេញ**) ។
- អាចដាក់ពាក្យស្នើសុំជាលក្ខណៈបុគ្គល ឬ ជាក្រុម (ចំពោះការដាក់ពាក្យស្នើសុំលក្ខណៈជាក្រុម សូមដាក់ឈ្មោះតែអ្នកតំណាងក្រុមបានហើយ) ។
- បេក្ខជនត្រូវពន្យល់ប្រាប់ពីមូលហេតុក្នុងការជ្រើសរើសយកអ្នកប្រឹក្សាផ្នែកសិល្បៈមកជួយនៅក្នុងគម្រោងរបស់ខ្លួន ។
  - លក្ខណសម្បត្តិ
  - ភាពស៊ីគ្នានៃចំណេះ និងជំនាញអ្នកប្រឹក្សាសិល្បៈទៅនឹងគម្រោងដែលស្នើសុំ
- ជាបេក្ខជនដែលកំពុងស្នាក់នៅក្នុងប្រទេសកម្ពុជាអំឡុងពេលនៃការអនុវត្តគម្រោង និងមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ លិខិតឆ្លងដែន ឬ ទិដ្ឋាការ K-Visa ។

**៥. គម្រោងនិងរយៈពេល**

- គម្រោងដែលទទួលបានមូលនិធិនេះ ត្រូវតែអនុវត្តនៅចន្លោះខែកក្កដា និង ខែធ្នូ ឆ្នាំ ២០២៤ ។
- **បញ្ជាក់៖** អ្នកទទួលបានមូលនិធិ ត្រូវតែបង្ហាញនៅក្នុងពាក្យស្នើសុំអំពីរយៈពេលនៃការអនុវត្តគម្រោង ពោលគឺការដាក់កាលបរិច្ឆេទឱ្យបានច្បាស់លាស់ (រយៈពេលនៃការអនុវត្តគម្រោងយ៉ាងតិចបំផុតមានរយៈពេល **៣ ខែ**) ។

**៦. ក្រុមការងារសម្របសម្រួលមូលនិធិ**

- មូលនិធិនេះ សម្របសម្រួលដោយ លោក ថា សំអាត ដែលអាចទំនាក់ទំនងតាមរយៈលេខទូរសព្ទ័ **០៧៧ ៧៩ ៣៥ ៣៧/០១០ ៤៨៣៩៤៧** និងអ៊ីម៉េល samath@cambodianlivingarts.org ។

**៧. អំពីកាលបរិច្ឆេទសំខាន់ៗ**

- **ដំណាក់កាលទី ១ ៖** ថ្ងៃទី ២១ ខែឧសភា ឆ្នាំ ២០២៤ - ការបើកប្រកាសទទួលពាក្យស្នើសុំមូលនិធិដំឡើងស្នាដៃថ្មី
- **ដំណាក់កាលទី ២ ៖** ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០២៤ - ការបិទទទួលពាក្យ
- **ដំណាក់កាលទី ៣ ៖** ថ្ងៃទី ៩ ខែកក្កដា ឆ្នាំ ២០២៤ - ការប្រកាសអ្នកទទួលបានមូលនិធិ

**លក្ខណៈសម្បត្តិបេក្ខជនត្រូវមាន**

ដើម្បីអាចចូលរួមកម្មវិធីបាន បេក្ខជនត្រូវ៖

- បង្ហាញពីឆន្ទៈនិងការតាំងចិត្តខ្ពស់និងពេលវេលាគ្រប់គ្រាន់ក្នុងការអនុវត្តគម្រោងឱ្យបានសម្រេចជោគជ័យ ។
- បង្ហាញពីចំណាប់អារម្មណ៍ផ្ទាល់ខ្លួន, ជីវប្រវត្តិនៅក្នុងវិស័យសិល្បៈ និងការបង្ហាញពីគម្រោងបង្កើតស្នាដៃថ្មី ។
- បង្ហាញពីចក្ខុវិស័យនៃគម្រោងស្នាដៃបង្កើតថ្មីរបស់អ្នក ថាតើវាសមស្របទៅនឹងមូលបទដូចម្តេចខ្លះ និងមានផលជះដល់ការសង្គមនិងសិល្បៈដោយរបៀបណា ។

សិល្បៈខ្មែរអមតៈ ប្តេជ្ញាចិត្តគាំទ្រដល់បេក្ខជនទាំងអស់ ដោយគ្មានការរើសអើងអំពីអាយុ ពិការភាព ជនជាតិដើមភាគតិច ភេទ អត្ត-សញ្ញាណ ស្ថានភាពគ្រួសារ សាសនា និងស្ថានភាពសេដ្ឋកិច្ចគ្រួសារឡើយ ។ យើងសូមលើកទឹកចិត្ត ជាពិសេសចំពោះបេក្ខជនមកពីសហគមន៍ ដែលមានសំឡេងតិច ហើយយើងនឹងផ្តល់ការគាំទ្រចំពោះតម្រូវការចាំបាច់បេក្ខជន ដែលទទួលមូលនិធិ ។ ពួកយើងចង់គាំទ្រដល់អ្នកដែលមិនធ្លាប់ទទួលបានឱកាសបែបនេះពីមុនមក ។

**របៀបដាក់ពាក្យ**

សូមបំពេញព័ត៌មានរបស់អ្នកនិងឆ្លើយសំណួរនៅក្នុងពាក្យស្នើសុំដែលអាចទាញយកតាមរយៈ តំណភ្ជាប់នេះ

| |
|---|
| វគ្គសំណួរនិងចម្លើយ<br>ពួកយើងនឹងបើកវេទិកាសំណួរចម្លើយតាមអនឡាញ ដែលលោកអ្នកនឹងមានឱកាសជួបជាមួយនឹង «ក្រុមការងារអង្គការសិល្បៈអមតៈ» ដើម្បី ពិភាក្សាជុំវិញមូលនិធិ និងដំណើរការ នៃការដាក់ពាក្យ។<br>កាលបរិច្ឆេទ៖ **ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៤** ចាប់ពី ម៉ោង៥:៣០ដល់ម៉ោង៧:00ល្ងាច ដោយចូលតាមតំណភ្ជាប់ខាងក្រោម៖<br>Zoom link: https://us02web.zoom.us/j/84133241789?pwd=ZFU2V20xdG8xM1VwR2FPeElPR2VHUT09<br>Meeting ID: 841 3324 1789<br>Passcode: 459289 |